# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ២៣ ខែមករា ឆ្នាំ២០១៣

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 29-Jan-2013, 11:29
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# សេចក្តីជំទាស់របស់ អៀង សារី ទៅនឹងការទទួលយកឯកសារមួយចំនួន

---

**ដាក់ដោយ:**

**ក្រុមមេធាវីការពារក្តី អៀង សារី**

អាង ឧត្តម

Michael G. KARNAVAS

**ចម្លងជូន:**

**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង:**

ចៅក្រម **និល ណុន**

ចៅក្រម **យ៉ា ខុត្តារ**

ចៅក្រម **យ៉ា សុខន**

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបម្រុង **ធូ មន្នី**

ចៅក្រមបម្រុង Claudia FENZ

០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

**សហព្រះរាជអាជ្ញា៖**

ជា លាង

Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") លោក អៀង សារី សូមដាក់សេចក្តីជំទាស់របស់គាត់នៅក្នុងឧបសម្ព័ន្ធមួយចំនួនដែលភ្ជាប់មកជាមួយ ពាក់ព័ន្ធនឹងការទទួលយកឯកសារមួយចំនួន និងសូមបញ្ជាក់បំភ្លឺអំពីឯកសារដែលគាត់បានជំទាស់ ដោយអនុលោមតាមវិធាន ៨៤(១) និងវិធាន ៨៧(៣)។ **ឧបសម្ព័ន្ធ ១** មានសេចក្តីជំទាស់ទៅនឹងឯកសារទាំងប៉ុន្មានដែល ក.ស.ព បានស្នើឡើង ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលទី ១[1]។ **ឧបសម្ព័ន្ធ ២** មានសេចក្តីជំទាស់ទៅនឹងឯកសារទាំងឡាយដែលត្រូវបានស្នើឡើងដោយ ក.ស.ព ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទី ២[2]។ **ឧបសម្ព័ន្ធ ៣** មានសេចក្តីជំទាស់ទៅនឹងឯកសារទាំងប៉ុន្មានដែល ក.ស.ព បានស្នើឡើង ទាក់ទងនឹងករណីទួលពោធិ៍ជ្រៃ[3]។ **ឧបសម្ព័ន្ធ ៤** មានសេចក្តីជំទាស់ទៅនឹងឯកសារទាំងប៉ុន្មានដែល ក.ស.ព បានកំណត់ថាជា "ឯកសារនៅសំខាន់ៗមកពីគ្រប់ភាគីទាំងអស់រួមគ្នាដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះ"[4]។ **ឧបសម្ព័ន្ធ ៥** មានសេចក្តីជំទាស់ទៅនឹងឯកសារទាំងប៉ុន្មានដែលមាននៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយ ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធយោធា ការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទី ១ និងទី២ និងករណីទួលពោធិ៍ជ្រៃ ដែលពុំទាន់ត្រូវបានលើកយកមកពិនិត្យពិចារណានៅក្នុងសវនាការលើការជំទាស់ឯកសារមុនៗ[5]។ ចម្លើយសាក្សីដែល ក.ស.ព បានស្នើឡើងនៅក្នុងឯកសារ E208, E208/1 និង E96/8

---

[1] *សូមមើល* ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងសុំឲ្យបញ្ជាក់ឯកសារបន្ថែមដែលពាក់ព័ន្ធនឹងវគ្គសវនាការស្តីពីការជម្លៀសប្រជាជន និងទួលពោធិ៍ជ្រៃ និងញត្តិស្នើសុំកំណត់កាលវិភាគសម្រាប់សវនាការដេញដោលលើឯកសារ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារ E223/2/1 និងឯកសារភ្ជាប់ជាឧបសម្ព័ន្ធ E223/2/1.2។

[2] *សូមមើល* ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងសុំឲ្យបញ្ជាក់ឯកសារបន្ថែមដែលពាក់ព័ន្ធនឹងវគ្គសវនាការស្តីពីការជម្លៀសប្រជាជន និងទួលពោធិ៍ជ្រៃ និងញត្តិស្នើសុំកំណត់កាលវិភាគសម្រាប់សវនាការដេញដោលលើឯកសារ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារ E223/2/1 និងឯកសារភ្ជាប់ជាឧបសម្ព័ន្ធ E223/2/1.3 ។

[3] *សូមមើល* ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងសុំឲ្យបញ្ជាក់ឯកសារបន្ថែមដែលពាក់ព័ន្ធនឹងវគ្គសវនាការស្តីពីការជម្លៀសប្រជាជន និងទួលពោធិ៍ជ្រៃ និងញត្តិស្នើសុំកំណត់កាលវិភាគសម្រាប់សវនាការដេញដោលលើឯកសារ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារ E223/2/1 និងឯកសារភ្ជាប់ជាឧបសម្ព័ន្ធ និង E223/2/1.4។

[4] *សូមមើល* ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងសុំឲ្យបញ្ជាក់ឯកសារបន្ថែមដែលពាក់ព័ន្ធនឹងវគ្គសវនាការស្តីពីការជម្លៀសប្រជាជន និងទួលពោធិ៍ជ្រៃ និងញត្តិស្នើសុំកំណត់កាលវិភាគសម្រាប់សវនាការដេញដោលលើឯកសារ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារ E223/2/1 កថាខណ្ឌ ៣ និងឧបសម្ព័ន្ធ E223/2/1.1។

[5] អនុលោមតាមអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "សវនាការដេញដោលលើឯកសារពេលខាងមុខ និងចម្លើយតបទៅនឹងអនុស្សរណៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំកំណត់អត្តសញ្ញាណនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ប្រើប្រាស់នៅសវនាការ" (ឯកសារ E208/4) និងសំណើរបស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន ស្នើសុំកែតម្រូវបញ្ជីភស្តុតាងគាំទ្រ (ឯកសារ E223)" ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ ឯកសារ E223/2 កថាខណ្ឌ ៥។

ពុំត្រូវបានដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធ៥ ឬឯកសារដីកាដំណោះស្រាយចំនួន២ ពុំត្រូវបាន ក.ស.ព បង្ហាញអត្តសញ្ញាណនៅក្នុងឯកសារ E223/2.1 ឡើយ (ដែលត្រូវបានលើកឡើងនៅក្នុងឧបសម្ព័ន្ធ ៤ របស់មេធាវីការពារក្តី)។ មេធាវីការពារក្តីដាក់សេចក្តីជំទាស់ដែលត្រូវបានបំពេញបន្ថែមដោយសេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់មេធាវីការពារក្តីកាលពីថ្ងៃទី ២១ និងថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៣ ទាំងនេះ ដើម្បីជួយដល់អង្គជំនុំជម្រះសាលាដំបូង ក្នុងការសម្រេចអំពីលទ្ធភាពទទួលយកឯកសារជាក់លាក់មួយចំនួនជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ និងដើម្បីបង្កើនភាពច្បាស់លាស់ និងសច្ចភាពពាក់ព័ន្ធនឹងគោលជំហររបស់មេធាវីការពារក្តីលើឯកសារនីមួយៗ។ ដោយហេតុថាមេធាវីការពារក្តីពុំមានតួនាទីដើម្បីវាយតម្លៃអំពីយថាភាពនៃឯកសារទាំងនេះ មេធាវីការពារក្តីសូមជំទាស់ទៅនឹងការទទួលយកឯកសារទាំងអស់ដែលពុំមានយថាភាពជាក់លាក់ ឬឯកសារដែលត្រូវបានបង្ហាញថាជាឯកសារយថាភូតពីសំណាក់ភាគីដែលស្នើសុំបង្ហាញឯកសារនោះ។ ជាចុងក្រោយ ដើម្បីជាប្រយោជន៍នៃភាពច្បាស់លាស់បន្ថែមទៀតពាក់ព័ន្ធនឹងឧបសម្ព័ន្ធ ៥ មេធាវីការពារក្តីសូមធ្វើសេចក្តីសន្និដ្ឋានដូចខាងក្រោម៖

១. ក្នុងអំឡុងសវនាការលើការជំទាស់ឯកសារកាលពីថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៣ ក្រោយពេលសំណៅចម្លងនៃឯកសារឧបសម្ព័ន្ធ ៥ (ដែលមានធ្វើបញ្ជីឯកសារចំនួន ៥៤) ត្រូវបានចែកទៅភាគីជំនួយការព្រះរាជអាជ្ញា Vincent De Wilde d'Estmael បានអះអាងថា ក្នុងចំណោមឯកសារទាំងឡាយដែលត្រូវបានដាក់បញ្ចូលក្នុងឧបសម្ព័ន្ធ ៥ មានឯកសារចំនួន ២៤ ដែលពុំគួរបើកចំហសម្រាប់ការពិភាក្សាដេញដោល[6]។ ថ្វីបើ ក.ស.ព មានភាពត្រឹមត្រូវដែលថាឯកសារចំនួន ១៦ ដូចមានរៀបរាប់នៅក្នុងសំណៅចម្លងនៃឧបសម្ព័ន្ធ ៥ ពិតជាធ្លាប់ត្រូវបានដាក់ឲ្យស្ថិតក្រោមការលើកទឡ្ហីករណ៍ផ្ទាល់មាត់ ឬត្រូវបានសម្រេចកាលពីពេលកន្លងទៅក៏ដោយ ក៏ ក.ស.ព ពុំមានភាពត្រឹមត្រូវអំពីឯកសារចំនួន ៨ ក្នុងចំណោមឯកសារទាំងអស់នេះ[7]។ មេធាវីការពារក្តីបានកែសម្រួលឧបសម្ព័ន្ធ៥ដោយបានដកចេញឯកសារទាំងអស់ដែលត្រូវបានជំទាស់ ឬសម្រេចរួចហើយ។ ឧបសម្ព័ន្ធ៥ ដាក់បញ្ចូលនូវហេតុផលចំពោះការរក្សាទុកឯកសារនីមួយៗនៃឯកសារចំនួនទាំង៨នេះ ប៉ុន្តែមេធាវីការពារក្តីសូមផ្តល់ការពន្យល់បន្ថែមដូចខាងក្រោមដើម្បីជាផលប្រយោជន៍នៃតម្លាភាព។

***ឯកសារ D108/28.48***

---

[6] *សូមមើល* ប្រតិចារឹកព្រាង, ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៣, ទំព័រ ៥៣-៥៩, ដោយយោងទៅដល់ឯកសារ **D108/28.28**, **D108/31.28**, **D125/97**, **D199/26.2.209**, **D199/26.2.219**, **D199/26.2.228**, **D199/26.2.256**, **D232/65**, **D233/8**, **D269/9/1.16**, **D299.1.15R**, **D304/1.3**, **D313/1.2.65**, **D365/1.1.10**, **D365/1.1.15**, **D365/1.1.17**, **D365/1.1.23**, **D365/1.1.28**, **D365/1.1.3**, **D365/1.1.34**, **D369/6**, **IS13.30** និងឯកសារ **IS13.31**។

[7] ឯកសារ **D108/28.48**, **D108/31.28**, **D125/97**, **D232/65**, **D233/8**, **D369/6**, **IS13.31** និងឯកសារ **IS19.71**។

២. ឯកសារនេះត្រូវបានចៅក្រម Lavergne បង្ហាញទៅសាក្សី មាស វឿន កាលពីថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២ (បើទោះបីជាលេខឯកសារដែលត្រូវបានបញ្ជាក់នៅក្នុងសំណៅភាសាអង់គ្លេសនៃប្រតិចារឹកនេះ ពុំត្រឹមត្រូវក៏ដោយ)[8]។ សាក្សីបានត្រឹមតែគូសបញ្ជាក់ថា គាត់ពុំបានដឹងអំពីការប្រជុំដែលមានលើកឡើងនៅក្នុងឯកសារនេះឡើយ។ ពុំមានការធ្វើអត្ថាធិប្បាយណាមួយបន្ថែមទៀតស្តីពីឯកសារនេះឡើយ។ នាពេលកន្លងមក មេធាវីការពារក្តីពុំត្រូវបានផ្តល់ឱកាសដើម្បីជំទាស់ទៅនឹងឯកសារនេះទេ។ ដោយហេតុថាពុំមាននីតិវិធីណាមួយត្រូវបានដាក់ឲ្យអនុវត្តក្នុងករណីដែលមានការរំពឹងថាភាគីនឹងជំទាស់ទៅនឹងឯកសារណាមួយ នៅពេលឯកសារទាំងនោះត្រូវបានចៅក្រមបង្ហាញទៅសាក្សី ទើបឯកសារនេះត្រូវបានដាក់បញ្ចូលក្នុងឧបសម្ព័ន្ធ ៥[9]។

***ឯកសារ D125/97, D232/65, D233/8, D369/6 និង IS19.71***

៣. ឯកសារចំនួនទាំង ៥ នេះជាចម្លើយសាក្សីដែលត្រូវបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ ដែលត្រូវបានដាក់បញ្ចូលក្នុងបញ្ជីឯកសារនៃខែ កក្កដា ឆ្នាំ ២០១១ របស់ ក.ស.ព ក្រោមឧបសម្ព័ន្ធ ១២ របស់ ក.ស.ព[10]។ ឧបសម្ព័ន្ធនេះត្រូវបានដកចេញពីការពិភាក្សានៅក្នុងសវនាការដេញដោលលើឯកសារកាលពីពេលកន្លងទៅ[11]។ កាលពីខែ មិថុនា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចរបស់ខ្លួនលើសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដោយអនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកចម្លើយសាក្សី និងឯកសារផ្សេងៗនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[12]។ នៅក្នុងសេចក្តីសម្រេចនេះ អង្គជំនុំជម្រះសាលាដំបូងបានណែនាំឲ្យ ក.ស.ព៖ **ក.**

---

[8] *សូមមើល* ប្រតិចារឹក, ថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២, ឯកសារ E1/131.1 ទំព័រ ៥២។

[9] *សូមមើល* ប្រតិចារឹកព្រាង, ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៣, ទំព័រ ៦៤-៦៥ ដែលមេធាវីការពារក្តីបានស្នើសុំការបញ្ជាក់បំភ្លឺអំពីបញ្ហានេះ។

[10] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំឯកសារទាក់ទងនឹងសវនាការដំណាក់កាលដំបូង, ឧបសម្ព័ន្ធ ១២ - ចម្លើយសាក្សី, ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១, ឯកសារ E109/4.12។

[11] *សូមមើល* អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើង "បច្ចុប្បន្នភាពទៅលើអនុស្សរណៈស្តីពីសវនាការលើឯកសារនៅដំណាក់កាលបន្ទាប់ (ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១២ ដល់ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២)" ឯកសារ E172/5 ជើងទំព័រលេខ១៖ "ឯកសារប្រភេទ A12 និង A13 នឹងត្រូវសម្រេចតាមរយៈការសម្រេចជាលាយលក្ខណ៍អក្សរដែលកំពុងស្ថិតក្រោមការពិចារណារបស់អង្គជំនុំជម្រះ។ ហេតុដូច្នេះនៅដំណាក់កាលនេះ ឯកសារទាំង២ប្រភេទនេះនឹងពុំត្រូវបានកំណត់យកមកដេញដោលនៅក្នុងសវនាការផ្ទាល់មាត់លើឯកសារឡើយ"។

[12] សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២, ឯកសារ E96/7។

ពិនិត្យមើលឡើងវិញនូវរាល់ឯកសារដែលមាននៅលើបញ្ជីចម្លើយសាក្សីរបស់ខ្លួន[13] ដើម្បីឲ្យស្រប ជាមួយលក្ខណៈវិនិច្ឆ័យស្ដីពីភាពអាចទទួលយកបាន ដែលបានកំណត់នៅក្នុងសេចក្ដីសម្រេចនេះ **ខ.** បញ្ជាក់គោលបំណងនៃភស្តុតាងរបស់ឯកសារនីមួយៗដែលត្រូវបានស្នើសុំដាក់នៅចំពោះមុខ អង្គជំនុំជម្រះ **គ.** ពិចារណាអំពីការស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះតែភស្តុតាងមួយសម្រាប់ ជាគំរូដែលតំណាងឲ្យប្រភេទនៃភស្តុតាងនីមួយៗ និង **ឃ.** ផ្តល់ការបញ្ជាក់ច្បាស់លាស់អំពីចំណុច ខាងលើត្រឹមថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២[14]។ ក.ស.ព បានអនុវត្តតាមសេចក្ដីណែនាំទាំងនេះ តាមរយៈការដាក់សំណើបន្ថែមរបស់សហព្រះរាជអាជ្ញា ស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនូវ ចម្លើយជាលាយលក្ខណ៍អក្សរ និងប្រតិចារឹក រួមជាមួយឧបសម្ព័ន្ធសម្គាល់ ១ ដល់ ១៦[15]។ ចម្លើយ សាក្សីចំនួនទាំង ៥ ដូចមានបង្ហាញក្នុងឧបសម្ព័ន្ធ ៥ របស់មេធាវីការពារក្ដី ពុំត្រូវបានដាក់បញ្ចូល ក្នុងសំណើរបស់ ក.ស.ព នេះឡើយ។ ចម្លើយទាំងនេះក៏ពុំត្រូវបានដាក់បញ្ចូលក្នុងសំណើ ២ ផ្សេង ទៀតរបស់ ក.ស.ព ដែល ក.ស.ព បានដាក់អនុលោមតាមសេចក្ដីណែនាំរបស់អង្គជំនុំជម្រះ សាលាដំបូងដែរ[16]។ ហេតុដូច្នេះ ចម្លើយសាក្សីទាំង ៥ នេះនឹងពុំមែនជាកម្មវត្ថុនៃសវនាការនៅថ្ងៃ ខាងមុខឡើយដោយហេតុថា៖

ក. ចម្លើយទាំងនេះពុំត្រូវបាន ក.ស.ព ស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ តទៅ ទៀតឡើយ ហើយ

---

[13] មុនពេលចេញសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ក.ស.ព បានដាក់សំណើបន្ថែមចំនួន ២ ស្នើសុំការទទួលយក ចម្លើយសាក្សី។ *សូមមើល* សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឲ្យទទួលយកចម្លើយសាក្សីពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជា ជននៅដំណាក់កាលទី ១, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១២, ឯកសារ E208។ សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឲ្យទទួល យកចម្លើយសាក្សីនានាដែល ទាក់ទងនឹងដំណាក់កាលទី ២ នៃការជម្លៀសប្រជាជន និងបញ្ហាភស្តុតាងផ្សេងទៀតជាមួយឧប សម្ព័ន្ធសម្គាល់ I, II, III និងឧបសម្ព័ន្ធ IV សាធារណៈ, ថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១២, ឯកសារ E208/2។

[14] សេចក្ដីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្ដាប់ ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២, ឯកសារ E96/7 កថា ខណ្ឌ ៣៥។

[15] សំណើបន្ថែមរបស់សហព្រះរាជអាជ្ញាដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងប្រតិចារឹក ជាមួយឧបសម្ព័ន្ធសម្គាល់ពី ១-១៦, ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២, ឯកសារ E96/8។

[16] សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឲ្យទទួលយកចម្លើយសាក្សីពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទី ១, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១២, ឯកសារ E208។ សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឲ្យទទួលយកចម្លើយសាក្សីនានាដែល ទាក់ទងនឹងដំណាក់កាលទី ២ នៃការជម្លៀសប្រជាជន និងបញ្ហាភស្តុតាងផ្សេងទៀត ជាមួយឧបសម្ព័ន្ធសម្គាល់ I, II, III និងឧប សម្ព័ន្ធ IV សាធារណៈ, ថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១២, ឯកសារ E208/2។

ខ. អង្គជំនុំជម្រះសាលាដំបូង បានណែនាំឲ្យភាគីលើកឡើងនៅក្នុងសវនាការដេញដោលលើឯកសារ *ទេ.នូវ៖* ""ឯកសារទាំងអស់ដែលត្រូវបានលើកយកមកធ្វើជាសំអាង នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយ ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១ និងទី ២) និងកន្លែងសម្លាប់មនុស្សនៅទួលពោធិជ្រៃតួយ៉ាងដូចជាកថាខណ្ឌ ២០៥-២០៩, ៦៩៨-៧១១, ៩៧៥-៩៧៧, ១១០៥-១១១៣, ១១៩១-១១៩៣, ១៣៧៥ និង ១៣៨៤ ព្រមទាំង "សេចក្តីថ្លែងទាំងឡាយដែលបានបង្ហាញនៅក្នុងកថាខណ្ឌ ២៨ នៃឯកសារ E96/7 (ឯកសារ ឬភស្តុតាងផ្សេងៗដែលត្រូវបានយោងត្រង់ជើងទំព័រនៃដីកាដំណោះស្រាយត្រង់ផ្នែកពាក់ព័ន្ធ) ដែលបានទទួលចំណាត់ថ្នាក់E3រួចហើយ ប៉ុន្តែពុំទាន់ត្រូវបានអង្គជំនុំជម្រះពិចារណានៅក្នុងសវនាការដេញដោលលើឯកសារមុនៗ"[17]។

***ឯកសារ D108/31.28 និង IS13.31***

៤. យោងតាម ក.ស.ព ឯកសារទាំង ២ នេះដូចគ្នាជាមួយឯកសារផ្សេងៗនៅក្នុងសំណុំរឿង ដែលត្រូវបានទទួលយករួចហើយ[18]។ បើទោះបីជាយ៉ាងណា ឯកសារទាំង២នេះ *ពុំ* ហាក់ដូចជាដូចគ្នាជាមួយឯកសារទាំង២ដែលត្រូវបានទទួលយកឡើយ យ៉ាងហោចណាស់ក្នុងសំណៅជាភាសាអង់គ្លេស[19]។ ជាឧទាហរណ៍ ឯកសារ D108/31.28 លើកឡើងអំពីមនុស្សម្នាក់ឈ្មោះ "សុខ" និងមនុស្សម្នាក់ទៀតឈ្មោះ "ឡាយ ជា" ចំណែកឯកសារD108/7.3 / E3/1049[20](ដែល ក.ស.ព អះអាងថាដូចគ្នា) លើកឡើងអំពីមនុស្សឈ្មោះ "សុង" និង "ឡាយ" ។ សំណៅភាសាអង់គ្លេសនៃឯកសារ IS13.31 មានសំណៅបកប្រែភាសាជាអង់គ្លេសបន្ថែមមួយ ដែលពុំត្រូវបានដាក់បញ្ចូលនៅក្នុងឯកសារ D248/6.1.5 / E3/822 (ដែលជាឯកសារដែល ក.ស.ព អះអាងថាដូចគ្នា)។

---

[17] *សូមមើល* សវនាការដេញដោលលើឯកសារនាពេលខាងមុខ និងចម្លើយតបទៅនឹងអនុស្សរណៈរបស់សហមេធាវីនាំមុខពាក់ព័ន្ធនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំកំណត់អត្តសញ្ញាណនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ប្រើប្រាស់នៅសវនាការ (ឯកសារ E208/4) និងសំណើរបស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន ស្នើសុំកែតម្រូវបញ្ជីភស្តុតាងគាំទ្រ (ឯកសារ E223)" ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២, ឯកសារ E223/2 កថាខណ្ឌ ៥។

[18] *សូមមើល* ប្រតិចារិកព្រាង, ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៣, ទំព័រ ៥៤,៥៨។

[19] ឯកសារ D108/31.28 ពុំមានសំណៅភាសាខ្មែរ ឬបារាំងនៅក្នុងសំណុំរឿងឡើយ។

[20] ឯកសារ D108/7.3 ហាក់ដូចជាស្ថិតនៅក្នុងសំណុំរឿង ក្នុងនាមជាឯកសារ D2-15.21ផងដែរ លើកលែងត្រង់ថា ឯកសារ D2-15.21 មានឯកសារភាសាខ្មែរចំនួន ២ ដែលត្រូវបានបង្ហាញនៅក្រោមលេខឯកសារដដែលតែមួយ ហើយឯកសារទាំងនេះហាក់ដូចជាឯកសារខុសគ្នាទាំងស្រុង។

មេធាវីការពារក្ដីគួរតែប្រមានឱកាសដើម្បីជំទាស់ទៅនឹងសំណៅទាំងនេះ ដែលត្រូវបានលើកយកមកធ្វើជាសំអាងនៅក្នុងដីកាដំណោះស្រាយ និងដែលពុំទាន់បានទទួលចំណាត់ថ្នាក់ E3 ដោយហេតុថាឯកសារទាំងនេះគឺជាឯកសារដែល ក.ស.ច.ស លើកយកមកសំអាង។

ហេតុដូច្នេះ តាមសំអាងហេតុទាំងអស់ដូចបានបញ្ជាក់ក្នុងឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ មេធាវីការពារក្ដីសូមគោរពស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង**បដិសេធ**ឯកសារទាំងឡាយ ដែលត្រូវបានជំទាស់នៅក្នុងសេចក្ដីជំទាស់នេះ។

សូមអង្គជំនុំជម្រះទទួលនូវក្ដីគោរពអំពីយើងខ្ញុំ។

| | |
|---|---|
| អាង ឧត្តម | Michael G. KARNAVAS |

សហមេធាវីរបស់លោក អៀង សារី

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី **២៣ ខែ មករា ឆ្នាំ ២០១៣**